ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៣២១ ឧវបន/ប្រក

# ប្រកាស
# ស្តីពី
# ការតែងតាំងសមាសភាពក្រុមប្រឹក្សាបរធនបាលសហគ្រិនខ្មែរ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ ៣២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ ស្តីពីការបង្កើតសហគ្រិនខ្មែរជាបរធនបាលកិច្ច
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## សម្រេច

**ប្រការ១.**-

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាបរធនបាលសហគ្រិនខ្មែរ ដែលសរសេរជាអក្សរកាត់ថា "**ស.គ.ខ.**" ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ហែម វណ្ណឌី** | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ប្រធាន |
| ២. ឯកឧត្តម **ជាវ អានសាន** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |

| | | |
|---|---|---|
| ៣. ឯកឧត្តម **ជា កុកហុង** | អគ្គនាយករងអគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤. អ្នកឧកញ៉ា **សៀ ឬទ្ធី** | ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន វើលប្រ៊ីដ គ្រុប | សមាជិក |
| ៥.ឧកញ៉ា **សុខ ពិសិដ្ឋ** | សហស្ថាបនិក និងនាយកប្រតិបត្តិ ក្រុមហ៊ុនជីហ្គៀគ្រុប | សមាជិក |
| ៦. លោកបណ្ឌិត **ហោ សេរីវឌ្ឍន៍** | ប្រធានក្រុមប្រឹក្សាភិបាលសមាគម វិនិយោគ នវានុវត្តន៍ និងអភិវឌ្ឍន៍ | សមាជិក |
| ៧. ឯកឧត្តមបណ្ឌិត **ឈៀង វណ្ណមុនិណ្ណា** | នាយកប្រតិបត្តិសហគ្រិនខ្មែរ | សមាជិក |

**ប្រការ២**.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣**.-

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធានវិទ្យាស្ថាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១១រោចខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ហែម វណ្ណឌី**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការបី "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ